លេខ ៤៥ ចេញផ្សាយថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមីនា ឆ្នាំ២០២៥

និយ័តករបរធនបាលកិច្ច
គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា

## មាតិកា


- សិក្ខាសាលាស្ដីពី "ការផ្គូផ្គងធុរកិច្ច តាមរយៈយន្តការបរធនបាលកិច្ចនៅកម្ពុជា"........................... ទំព័រទី១
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថានអភិវឌ្ឍន៍ធនារ៉ាប់រងកូរ៉េ (KIDI)........................................................................ ទំព័រទី២
- កិច្ចប្រជុំបច្ចេកទេសស្ដីពី របាយការណ៍ត្រួតពិនិត្យការអនុវត្តថវិកាឆ្នាំ២០២៤......................... ទំព័រទី២
- កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០"......... ទំព័រទី២
- សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"............ ទំព័រទី៣
- សិក្ខាសាលាស្ដីពី "អនុលោមភាពច្បាប់ និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច".... ទំព័រទី៣
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមីនា ឆ្នាំ២០២៥...... ទំព័រទី៤
- កម្មវិធីអបអរសាទរខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥............................ ទំព័រទី៤
- កិច្ចប្រជុំពិភាក្សាស្ដីពី "ការបង្កើតមូលនិធិស្រាវជ្រាវជាតិជាបរធនបាលកិច្ច"............................ ទំព័រទី៤
- កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារវាយតម្លៃរបស់វេទិកាសកលស្ដីពីតម្លាភាព និងការផ្លាស់ប្ដូរព័ត៌មានដើម្បីគោលបំណងពន្ធ........................................................................ ទំព័រទី៥
- សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP.............................. ទំព័រទី៥
- វេទិកាបណ្ដាញហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសកល (Global Finance &Technology Forum)"...... ទំព័រទី៦
- វគ្គបណ្ដុះបណ្ដាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៦........................................................................ ទំព័រទី៦
- ការប្រគល់ថវិការបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃ ន.ប.ធ. ជូនមន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា................ ទំព័រទី៦
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យលើរបាយការណ៍បូកសរុបវឌ្ឍនភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤........................................................................ ទំព័រទី៧
- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៣................................................ ទំព័រទី៧
- សិក្ខាសាលាស្ដីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា"................................................ ទំព័រទី៧
- សិក្ខាសាលាស្ដីពី "ការវិវត្តថ្មីៗក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងវិធានការណ៍ជាយុទ្ធសាស្ត្រពាក់ព័ន្ធ" ទំព័រទី៨
- កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៤ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤........................................................................ ទំព័រទី៨
- កម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៦ ឆ្នាំ២០២៥............................ ទំព័រទី៩
- កិច្ចប្រជុំកំពូលអាស៊ីឆ្នាំ២០២៥ ស្ដីពី "ធនធានមនុស្ស និងបច្ចេកវិទ្យាការងារ-HR & WorkTech Asia Summit 2025"........................................................................ ទំព័រទី៩
- សិក្ខាសាលាស្ដីពី "បរធនបាលកិច្ចទីផ្សាររូបិយវត្ថុ និងជម្រើសពាក់ព័ន្ធ"................................ ទំព័រទី១០
- កិច្ចប្រជុំបិទកម្មវិធីអធិការកិច្ចហិរញ្ញវត្ថុ លើការគ្រប់គ្រងការអនុវត្តចំណូល-ចំណាយថវិកាការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០២២-២០២៣ និងឆ្នាំពាក់ព័ន្ធ.................... ទំព័រទី១០
- សិក្ខាសាលាស្ដីពី ប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និងខេអេចឃ្យូអរ......................................... ទំព័រទី១១
- សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែ-ច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"........................................ ទំព័រទី១១
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមីនា ឆ្នាំ២០២៥...... ទំព័រទី១១
- កិច្ចប្រជុំស្ដីពី "ការពិនិត្យវឌ្ឍនភាពការងារអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1)"........................................ ទំព័រទី១២
- កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចរបស់និយ័តករធានារ៉ាប់រងកម្ពុជា........................................................ ទំព័រទី១២
- សិក្ខាសាលាស្ដីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច"........................................................................ ទំព័រទី១៣
- កិច្ចប្រជុំចាប់ផ្ដើមកម្រិតថ្នាក់ដឹកនាំ (High level Kick-off) លើគម្រោងជំនួយបច្ចេកទេសស្ដីពីការរៀបចំ "របាយការណ៍ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ"..... ទំព័រទី១៣
- សិក្ខាសាលាស្ដីពី "ការចែករំលែកអំពីយន្តការបរធនបាលកិច្ចអចលនវត្ថុ"................................ ទំព័រទី១៤
- សិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈអំពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល"........................................................ ទំព័រទី១៤


## សិក្ខាសាលាស្ដីពី "ការផ្គូផ្គងធុរកិច្ច តាមរយៈយន្តការបរធនបាលកិច្ចនៅកម្ពុជា"

នាព្រឹកថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមីនា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច បាន (**ន.ប.ធ.**) រៀបចំសិក្ខាសាលាស្ដីពី "ការផ្គូផ្គងធុរកិច្ច តាមរយៈយន្តការបរធនបាលកិច្ចនៅកម្ពុជា" ដោយមានការចូលរួមសហការ រៀបចំជាមួយសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា (**ស.វ.អ.ក**) និងក្រុមហ៊ុន វេសឡាញ អេឌ្យូខេសិន គ្រុប ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

កម្មវិធីនេះត្រូវបានធ្វើឡើង ដើម្បីជំរុញការវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជា តាមរយៈយន្តការបរធនបាលកិច្ច ដែលអនុញ្ញាតឲ្យវិនិយោគិន ជាពិសេសវិនិយោគិនបរទេស អាចប្រើប្រាស់ថ្នាលតភ្ជាប់ ឬច្រកដ៏មានសុវត្ថិភាព និងមានប្រសិទ្ធភាព ដោយអាចស្វែងរកអចលនទ្រព្យ ដែលមានសក្ដានុពល មានមូលដ្ឋានព័ត៌មានច្បាស់លាស់ តាមរយៈអ្នកជំនាញការមានវិជ្ជាជីវៈខ្ពស់ក្នុងវិស័យ មានអាជ្ញាបណ្ណស្របច្បាប់ រហូតដល់ឈានទៅធ្វើការវិនិយោគ ដោយបង្កើតជាបរធនបាលកិច្ច អនុលោមតាមច្បាប់ និងគាំពារដោយច្បាប់ជាធរមាន រួមទាំងការវិនិយោគតាមរយៈយន្តការបរធនបាលកិច្ច មូលនិធិភាគហ៊ុនិក ផងដែរ។

កម្មវិធីនេះមានការអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសផ្ដល់បទបង្ហាញដោយ **លោក សន សៀប ប្រធាន ស.វ.អ.ក** និង **ឧកញ៉ា ម៉ិច ម៉ូឡៃន** អគ្គនាយក នៃក្រុមហ៊ុន វេសឡាញ អេឌ្យូខេសិន គ្រុប **ខូ អិលជីឌី** ផងដែរ ព្រមទាំងមានការអញ្ជើញចូលរួមពីប្រតិបត្តិករផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ច និងតំណាងសមាគមធុរកិច្ច និង



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

សភាពាណិជ្ជកម្មបរទេសជាច្រើននៅកម្ពុជា ដូចជា សភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា និងសភាពាណិជ្ជកម្មចិននៅកម្ពុជាជាដើម។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្តេផ្គងធុរកិច្ច តាមរយៈយន្តការបរធនបាលកិច្ច នៅកម្ពុជា"។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធនាប៉ាប់រងកម្ពុជា និងវិទ្យាស្ថានអភិវឌ្ឍន៍ធនាប៉ាប់រងកូរ៉េ (KIDI)

នាព្រឹកថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមីនា គ.ស.២០២៥ **ឯកឧត្តម នខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការីបានអញ្ជើញចូលរួមជាអធិបតីក្នុង "ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធនាប៉ាប់រងកម្ពុជា និងវិទ្យាស្ថានអភិវឌ្ឍន៍ធនាប៉ាប់រងកូរ៉េ (KIDI)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សេ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធនាប៉ាប់រងកម្ពុជា និងវិទ្យាស្ថានអភិវឌ្ឍន៍ធនាប៉ាប់រងកូរ៉េ (KIDI)។

## កិច្ចប្រជុំបច្ចេកទេសស្តីពី របាយការណ៍ត្រួតពិនិត្យការអនុវត្តថវិកាឆ្នាំ២០២៤

នារសៀលថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក យុន វាសនា ប្រធាននាយកដ្ឋានកិច្ចការទូទៅ** និងសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសស្តីពី របាយការណ៍ត្រួតពិនិត្យការអនុវត្តថវិកាឆ្នាំ២០២៤ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សេ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សារបស់ អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ស្ថាប័ន អង្គភាព ក្រោមឱវាទនៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំបច្ចេកទេសស្តីពី របាយការណ៍ត្រួតពិនិត្យការអនុវត្តថវិកាឆ្នាំ២០២៤។

## កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន ដែលជាសមាជិកនៃគណៈកម្មាធិការនេះ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០"។

## សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែមីនា គ.ស. ២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP" ក្រោមអធិបតីភាពរបស់ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការនៃ ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ. និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1** និងតំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសាវតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោល-នយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុរកិច្ច ដល់សមាជិក-សមាជិកាសហគមន៍កសិកម្ម សាមគ្គីមានជ័យ និងសាមគ្គីអូរឡោក ដែលស្ថិតនៅភូមិចំការគ និងភូមិអូរឡោក ឃុំចក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកផែនការអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយ សមាជិក/សមាជិកាសហគមន៍កសិកម្ម, មន្ត្រី និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ, និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។



រូបភាព៖ សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"។

## សិក្ខាសាលាស្ដីពី "អនុលោមភាពច្បាប់ និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមីនា គ.ស.២០២៥ នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាស្ដីពី "អនុលោមភាពច្បាប់ និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម នខ ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** ដោយមានការចូលរួមពីក្រុមហ៊ុនបរធនបាល, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, បរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ, ប្រតិបត្តិករបរធនបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យបរធនបាលកិច្ច សរុបចំនួន ១១០ រូប។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងផ្នែកអនុលោមភាពតាមច្បាប់ និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច ដើម្បីធានាបាននូវសណ្ដាប់ធ្នាប់ និងរបៀបរៀបរយក្នុងប្រតិបត្តិការគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ចស្របតាមច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច។



រូបភាព៖ សិក្ខាសាលាស្ដីពី "អនុលោមភាពច្បាប់ និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមីនា ឆ្នាំ២០២៥

នារសៀលថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមីនា គ.ស.២០២៥ **ឯកឧត្តម នខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមីនា ឆ្នាំ២០២៥ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច។

កិច្ចប្រជុំនេះ មានការចូលរួមពីលោកស្រីប្រធាននាយកដ្ឋាន លោកប្រធាននាយកដ្ឋានស្តីទី អនុប្រធាននាយកដ្ឋាន, ប្រធាន-ការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករង បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០២៥ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។

កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាព៖កិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមីនា ឆ្នាំ២០២៥។

## កម្មវិធីអបអរសាទរខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥

នាព្រឹកថ្ងៃសុក្រ ៩កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែមីនា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីអបអរសាទរខួបលើកទី១១៤ ទិវា-អន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥ ក្រោមមូលបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប"ចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **លោកជំទាវ ឱ បូរី** នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ ជាមួយគ្នានេះ ក៏មានការរៀបចំប្រគល់បាច់ផ្កា វត្ថុ-អនុស្សាវរីយ៍ និងប្រាក់ឧបត្ថម្ភដែលជាអំណោយដ៏ថ្លៃថ្លារបស់ **ឯក-ឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ( អ.ស.ហ.)** ផ្តល់ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីជានារីរបស់ **ន.ប.ធ.** ព្រមទាំងពិសារអាហារសាមគ្គីរួមគ្នាផងដែរ។



រូបភាព៖ កម្មវិធីអបអរសាទរខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥។

## កិច្ចប្រជុំពិភាក្សាស្តីពី "ការបង្កើតមូលនិធិស្រាវជ្រាវជាតិជាបរធនបាលកិច្ច"

នាព្រឹកថ្ងៃសុក្រ ៩កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី "ការបង្កើតមូលនិធិស្រាវជ្រាវជាតិជាបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយមានការចូលរួមរបស់ **ឯកឧត្តមបណ្ឌិត ស្តើង សុខុម** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតំណាងក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំពិភាក្សាស្តីពី "ការបង្កើតមូលនិធិស្រាវជ្រាវជាតិជាបរធនបាលកិច្ច"។

## កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារវាយតម្លៃរបស់វេទិកាសកលស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធ

នៅថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមីនា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ចនៃ ន.ប.ធ.** អមដោយក្រុមការងារ បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារវាយតម្លៃ (Assessment Team) របស់វេទិកាសកលស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធ (Global Forum) ដែលសហការរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ និង Assessment Team របស់វេទិកា Global Forum ព្រមទាំងមានការចូលរួមពីតំណាងក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និយ័តករគណនេយ្យនិងសវនកម្ម ធនាគារពាណិជ្ជ ក្រុមហ៊ុនបរធនបាល ក្រុមហ៊ុនវិជ្ជាជីវៈមេធាវី គណនេយ្យ សវនកម្ម និងភ្នាក់ងារសេវាកម្មពន្ធដារ នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។



រូបភាព៖ កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារវាយតម្លៃរបស់វេទិកាសកលស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធ។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"

ចាប់ពីថ្ងៃព្រហស្បតិ៍ ៨កើត ដល់ថ្ងៃសុក្រ ៩កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦-៧ ខែមីនា គ.ស. ២០២៥ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP" ក្រោមអធិបតីភាពរបស់ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** នៃ **ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និងតំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោល-នយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុកិច្ច ដល់សមាជិក-សមាជិកាសហគមន៍កសិកម្មចំនួន ៣ ដែលរួមមាន៖ សហគមន៍កសិកម្មបៃតងគោកស្រុក សហគមន៍កសិកម្មកសិករតំបែរ និងសហគមន៍កសិកម្មល្វៀងមានជ័យ ដែលស្ថិតនៅស្រុកតំបែរ និងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលមានបំណងស្វែងរកហិរញ្ញប្បទានគាំទ្រ និងពង្រីកផែនការអាជីវកម្មរបស់ខ្លួន។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកាសហគមន៍កសិកម្មខាងលើ, មន្ត្រី និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ, និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## វេទិកាបណ្តាញហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសកល (Global Finance & Technology Forum)

ចាប់ពីថ្ងៃចន្ទ-សុក្រ ៣-៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣-៧ ខែមីនា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួម "វេទិកាបណ្តាញហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសកល (Global Finance & Technology Forum)" នៅប្រទេសជប៉ុន ក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology-FinTech), ក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍ បញ្ហាប្រឈម និងនិន្នាការថ្មីៗនៃការវិវត្ត FinTech ជាសកល ក៏ដូចជាបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត ដែលមានសារសំខាន់ក្នុងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា។




រូបភាព៖ "វេទិកាបណ្តាញហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសកល (Global Finance & Technology Forum)"។

## វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៦

នាព្រឹកថ្ងៃចន្ទ ១២កើតខែផល្គុនឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញប្រកាសបើក "វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៦" ដែលរៀបចំដោយនិយ័តករបរធនបាលកិច្ច នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំរយៈពេលចំនួន ៣ ថ្ងៃពេញ ចាប់ពីថ្ងៃទី១០-១២ ខែមីនា ឆ្នាំ២០២៥ និងមានអ្នកចូលរួមសរុបចំនួន ១៧៣ រូប ដែលមានសមាសភាពចូលរួមពីក្រុមហ៊ុននិងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច,បុគ្គលដែលមានបំណងផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន។



រូបភាព៖ វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៦។

## ការប្រគល់ថវិការបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃ ន.ប.ធ. ជូនមន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា

នាព្រឹកថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម នេខ ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វាសនា ប្រធាននាយកដ្ឋានកិច្ចការទូទៅ** និងសហការី បាននាំយកថវិកាដែលជាការបរិច្ចាគពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** ប្រគល់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីចូលរួមចំណែកក្នុងការជួយសង្គ្រោះជីវិតកុមារកម្ពុជា និងធានានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា។



រូបភាព៖ ការប្រគល់ថវិការបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃ ន.ប.ធ. ជូនមន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យលើរបាយការណ៍បូកសរុបវឌ្ឍនភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤

នាព្រឹកថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមីនា គ.ស.២០២៥, **លោក យុន វាសនា ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃនិយ័តករបរធនបាលកិច្ច** និងជាសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី៥ នៃសមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**គសហវ**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យលើរបាយការណ៍បូកសរុបវឌ្ឍនភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ របស់សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការនៃ **គសហវ** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ កែវ ចរិយា** រដ្ឋលេខាធិការ និងជាប្រធានក្រុមប្រឹក្សាភិបាលសមាគមសង្គហៈមិត្ត បុគ្គលិកមន្ត្រីរាជការនៃ **គសហវ** ព្រមទាំងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលសមាគមសង្គហៈមិត្ត បុគ្គលិកមន្ត្រីរាជការនៃគសហវ នៅទីស្តីការ **គសហវ**។



រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យលើរបាយការណ៍បូកសរុបវឌ្ឍនភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៣

នាព្រឹកថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារបានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ និងឯកឧត្តមអគ្គនាយកដែលជាសមាជិក-សមាជិកានៃ **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំនៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៣។

## សិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា"

នារសៀលថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ថ្ងៃទី១១ ខែសីហា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីសិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា" ដោយមានការអញ្ជើញចូលរួមធ្វើបាឋកថាដោយ **ឯកឧត្តម អ៊ុំ លុយណា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

កម្មវិធីនេះមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងឱ្យនិយ័តករទាំងអស់ក្រោមឱវាទរបស់ **អ.ស.ហ.** ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវឧកញ៉ា លោក លោកស្រី តំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងសិក្ខាកាមនៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យបរធនបាលកិច្ច លើកទី៦ផងដែរ។



រូបភាព៖ សិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា"។

## សិក្ខាសាលាស្តីពី "ការវិវត្តថ្មីៗក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងវិធានការណ៍ជាយុទ្ធសាស្ត្រពាក់ព័ន្ធ"

នាព្រឹកថ្ងៃពុធ ១៤កើតខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែមីនា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាស្តីពី "ការវិវត្តថ្មីៗក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងវិធានការណ៍ជាយុទ្ធសាស្ត្រពាក់ព័ន្ធ" នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ កិច្ចពិភាក្សានេះ មានការអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយសដែលសុទ្ធសឹងជាអ្នកជំនាញក្នុងវិស័យបរធនបាលកិច្ច, វិស័យសំណង់ និងអចលនទ្រព្យ, វិស័យធនាគារ និងវិស័យអចលនវត្ថុ រួមមាន៖ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃ **ន.ប.ធ.**, **លោកបណ្ឌិត ហូ ចាន់ថា** អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, **លោក លន់ សំអុល ប្រធាននាយកដ្ឋានត្រួតពិនិត្យទី១** នៃធនាគារជាតិនៃកម្ពុជា, **លោកចាន់ ម៉ាច អគ្គនាយកនៃធនាគារហ្វីលីព ភីអិលស៊ី** និង **លោក ស៊ាផៃលីន អនុប្រធានសមាគម អ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា**។

នៅក្នុងកម្មវិធីនេះ វាគ្មិនកិត្តិយសបានផ្តោតការពិភាក្សាជាសំខាន់លើទស្សនទានវិស័យអចលនវត្ថុ និងតួនាទីនៃយន្តការបរធនបាលកិច្ច, គោលនយោបាយ និងវិធានការយុទ្ធសាស្ត្រដើម្បីជំរុញការអភិវឌ្ឍ និងដំណោះស្រាយបញ្ហាប្រឈមដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានដាក់ចេញ ក៏ដូចជា ភាពធន់ ភាពរឹងមាំ ក្នុងវិស័យធនាគារនៅកម្ពុជាក្នុងបរិការណ៍ឌីជីថល ព្រមទាំងការចូលរួមគាំទ្រពាក់ព័ន្ធនានាក្នុងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជាផងដែរ។

កម្មវិធីនេះក៏មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ និងឯកឧត្តម លោកជំទាវ លោកលោកស្រីតំណាងឱ្យនិយ័តករទាំងអស់ក្រោមឱវាទរបស់ **អ.ស.ហ.** ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** អ្នកឧកញ៉ា លោកឧកញ៉ា ក្នុងវិស័យបរធនបាលកិច្ច ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងសិក្ខាកាមនៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យបរធនបាលកិច្ចលើកទី៦ ផងដែរ។



រូបភាព៖ សិក្ខាសាលាស្តីពី "ការវិវត្តថ្មីៗក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងវិធានការណ៍ជាយុទ្ធសាស្ត្រពាក់ព័ន្ធ"។

## កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៤ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាគល** អគ្គនាយករង នៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៤ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួងស្ថាប័ន-អង្គភាព នៅសណ្ឋាគារ សូហ្វីតែលភ្នំពេញភូគីត្រា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖ កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៤ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤។

## កម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៦ ឆ្នាំ២០២៥

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៥ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៥ **ឯកឧត្តម នច ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច អមដោយ **លោក ណាង សេរីវុធ អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** និងសហការី បានអញ្ជើញចូលរួមកាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៦ ឆ្នាំ២០២៥ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។



រូបភាព៖កម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៦ ឆ្នាំ២០២៥។

## កិច្ចប្រជុំកំពូលអាស៊ីឆ្នាំ២០២៥ ស្ដីពី "ធនធានមនុស្ស និងបច្ចេកវិទ្យាការងារ-HR & WorkTech Asia Summit 2025"

នាថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែមីនា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុត តារាវិធ័យ អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ, លោក តឹក សុផានុ ប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិក និងលោកស្រី ពៅ សុជាតា អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានកិច្ចការទូទៅ** បានចូលរួមកិច្ចប្រជុំកំពូលអាស៊ីឆ្នាំ២០២៥ ស្ដីពី "ធនធានមនុស្ស និងបច្ចេកវិទ្យាការងារ-HR & WorkTech Asia Summit 2025" ដែលបានរៀបចំដោយក្រុមហ៊ុន Escom mav Pte. នៅប្រទេសសិង្ហបុរី។ កិច្ចប្រជុំនេះ បានផ្តោតសំខាន់លើការបង្កើនប្រសិទ្ធភាពការងារក្នុងការគ្រប់គ្រងធនធានមនុស្ស រួមមាន៖ ១.ការរៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្ស និងបច្ចេកវិទ្យា ( People & Technology Planning ), ២.ភាពជាអ្នកដឹកនាំ និងវប្បធម៌នៃកន្លែងធ្វើការ , ៣.បទពិសោធន៍ និងសុខុមាលភាពរបស់និយោជិត, ៤.ការផ្លាស់ប្តូរទិន្នន័យឌីជីថល បញ្ញាសិប្បនិម្មិត និងវិភាគទិន្នន័យ និង៥.ការបណ្តុះបណ្តាលជំនាញ និងការរៀនសូត្ររបស់និយោជិត។




រូបភាព៖ កិច្ចប្រជុំកំពូលអាស៊ីឆ្នាំ២០២៥ ស្ដីពី "ធនធានមនុស្ស និងបច្ចេកវិទ្យាការងារ-HR & WorkTech Asia Summit 2025"។

## សិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

ព្រឹកថ្ងៃចន្ទ ៤រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែមីនា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តសៀមរាប បានសហការគ្នារៀបចំសិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ច-ដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម នច ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និង **លោក ឈួន ភារុន នាយកសាខានៃសាកលវិទ្យាល័យបៀលប្រាយ** នៅសាកលវិទ្យាល័យបៀលប្រាយខេត្តសៀមរាប។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាប

ការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យបៀលប្រាយ ខេត្តសៀមរាប ចំនួន ១៣០ រូប។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"។

## សិក្ខាសាលាស្តីពី "បរធនបាលកិច្ចទីផ្សាររូបិយវត្ថុ និងជម្រើសពាក់ព័ន្ធ"

នាព្រឹកថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែមីនា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាស្តីពី "បរធនបាលកិច្ចទីផ្សាររូបិយវត្ថុ និងជម្រើសពាក់ព័ន្ធ" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

កម្មវិធីនេះត្រូវបានរៀបចំឡើង ដើម្បីចែករំលែកចំណេះដឹងដល់វិនិយោគិន និងតួអង្គពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចអំពី៖ ១-ឧបករណ៍បំណុលរយៈពេលខ្លីដែលមានគុណភាពល្អ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលមានសន្ទនីយភាពខ្ពស់តាមរយៈយន្តការបរធនបាលកិច្ច ឧទាហរណ៍ដូចជាបរធនបាលកិច្ចប្រាក់បញ្ញើអត្រាការប្រាក់ថេរជាដើម, ២-ការធ្វើពិពិធកម្មជម្រើសក្នុងការវិនិយោគតាមរយៈបរធនបាលកិច្ចទៅលើផលិតផលហិរញ្ញវត្ថុផ្សេងទៀតដែលផ្តល់ផលខ្ពស់ ហានិភ័យទាប ក្នុងខណៈពេលអត្រាការប្រាក់មានការធ្លាក់ចុះ ដូចជា៖ វិនិយោគលើមូលបត្ររដ្ឋ និងសញ្ញាបណ្ណសាជីវកម្មដោយផ្ទាល់ ឬ តាមរយៈយន្តការបរធនបាលកិច្ច និង ៣- ពិនិត្យនូវលំហរកាលានុវត្តភាពទាក់ទាញ និងការបង្កើតនូវជម្រើសបន្ថែមសម្រាប់វិនិយោគិនដែលមានអតិរេកសាច់ប្រាក់។

កម្មវិធីនេះមានការអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសផ្តល់បទបង្ហាញដោយ **លោក ឃឹម ហ្វាដាណេ** អគ្គនាយករង នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក សេង ចាន់ធឿន នាយកប្រតិបត្តិ នៃក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប សីយូរីធី ម.ក ផងដែរ ព្រមទាំងមានការអញ្ជើញចូលរួមពីប្រតិបត្តិករផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច និងតំណាងសមាគមធុរកិច្ច និងសភាពាណិជ្ជកម្មបរទេសជាច្រើននៅកម្ពុជាដូចជា សភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា សភាពាណិជ្ជកម្មអន្តរជាតិនៅកម្ពុជា និងសភាពាណិជ្ជកម្មចិននៅកម្ពុជាជាដើម។



រូបភាព៖ សិក្ខាសាលាស្តីពី "បរធនបាលកិច្ចទីផ្សាររូបិយវត្ថុ និងជម្រើសពាក់ព័ន្ធ"។

## កិច្ចប្រជុំបិទកម្មវិធីអធិការកិច្ចហិរញ្ញវត្ថុ លើការគ្រប់គ្រងការអនុវត្តចំណូល-ចំណាយថវិកាការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០២២-២០២៣ និងឆ្នាំពាក់ព័ន្ធ

នារសៀលថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក យុន វិសនា ប្រធាននាយកដ្ឋានកិច្ចការទូទៅ** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំបិទកម្មវិធីអធិការកិច្ចហិរញ្ញវត្ថុ លើការគ្រប់គ្រងការអនុវត្តចំណូល-ចំណាយថវិកាការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០២២-២០២៣ និងឆ្នាំពាក់ព័ន្ធ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និង **ឯកឧត្តម ឆាយ រតនៈ** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គាធិការនៃអគ្គាធិការដ្ឋាន **កសហវ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ស្ថាប័ន អង្គភាព ក្រោមឱវាទនៃ **អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំបិទកម្មវិធីអធិការកិច្ចហិរញ្ញវត្ថុ លើការគ្រប់គ្រងការអនុវត្តចំណូល-ចំណាយថវិកាការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០២២-២០២៣ និងឆ្នាំពាក់ព័ន្ធ។

## សិក្ខាសាលាស្តីពី ប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និង ខេអេចឃ្យូអរ

នាព្រឹកថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមីនា គ.ស.២០២៥ **ឯកឧត្តម ឈី - សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច ( **ន.ប.ធ.** ) តំណាងនិយ័តករបរធនបាលកិច្ច បានអញ្ជើញចូលរួមក្នុងពិធីអបអរ-សាទរ ខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ និង សិក្ខាសាលាស្តីពី ប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និងខេអេចឃ្យូអរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានរដ្ឋសភា។



រូបភាព៖ សិក្ខាសាលាស្តីពី ប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និងខេអេចឃ្យូអរ។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"

នាព្រឹកថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមីនា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែ-ច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈី សាកល** អគ្គនាយករងនៃ **ន.ប.ធ.**តំណាង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង **ឯកឧត្តម ស្រ៊ុន-ស្រ៊ន់** អភិបាលរងខេត្ត តំណាង **ឯកឧត្តម ជាម ច័ន្ទសោភ័ណ** អភិបាលនៃគណៈអភិបាល ខេត្តកំពង់ស្ពឺ នៅសាលាប្រជុំសែនក្រអូបនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ។

កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោល-នយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះដល់សមាជិក-សមាជិកាសហគមន៍កសិករ និងសហគ្រាសកសិធុរកិច្ចមួយចំនួន ដែលមានបំណងស្វែងរកទុនគាំទ្រ និងពង្រីកផែនការអាជីវកម្មរបស់ខ្លួន។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ, សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន÷ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមីនា ឆ្នាំ២០២៥

នាព្រឹកថ្ងៃចន្ទ ១១រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមីនា គ.ស. ២០២៥ **ឯកឧត្តម ឈី សាកល**



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមីនា ឆ្នាំ២០២៥ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃនិយ័តករបរធនបាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកប្រធានស្ដីទីនាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្ដមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០២៥ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋាន និងបានផ្ដល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមីនា ឆ្នាំ២០២៥។

## កិច្ចប្រជុំស្ដីពី "ការពិនិត្យវឌ្ឍនភាពការងារអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1)"

នារសៀលថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង **លោក លោក ឡុង-ពិសិដ្ឋ មន្ត្រីជាន់ខ្ពស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB និងជាប្រធានគ្រប់គ្រងគម្រោង ACSEP** ប្រចាំប្រទេសកម្ពុជា បានដឹកនាំកិច្ចប្រជុំស្ដីពី "ការពិនិត្យវឌ្ឍនភាពការងារអនុវត្តគម្រោងប្រកួតប្រជែងខ្សែ-ច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1)" នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យលើវឌ្ឍនភាពការងារក្នុងឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ និងដើម្បីពិភាក្សាលើបញ្ហាប្រឈម និងដំណោះស្រាយ ក្នុងដំណើរ-ការអនុវត្តគម្រោងពាក់ព័ន្ធនឹងដំណើរការប្រតិបត្តិការផ្នែកឥណទានក្នុងឆ្នាំ២០២៤ ព្រមទាំងដើម្បីរៀបចំយុទ្ធសាស្ត្រអនុវត្តឱ្យបានកាន់តែល្អប្រសើរ។ កិច្ចប្រជុំនេះ មានការចូលរួមដោយតំណាងសាជីវកម្មធានាឥណទានកម្ពុជា,សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងមកពីអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃ **ក.ស.ហ.វ.**, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ កិច្ចប្រជុំស្ដីពី "ការពិនិត្យវឌ្ឍនភាពការងារអនុវត្តគម្រោងប្រកួត-ប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1)"។

## កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចរបស់និយ័តករធានារ៉ាប់រងកម្ពុជា

នារសៀលថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមីនា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច, លោក វិន វឌ្ឍា ប្រធាននាយកដ្ឋានស្ដីទីនៃនាយកដ្ឋានចុះបញ្ជី** និងសហការី បានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចរបស់និយ័តករធានារ៉ាប់រងកម្ពុជា និងសេចក្ដីព្រាងប្រកាសស្ដីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង និងភ្នាក់ងារចែកចាយលក់មូលនិធិរបស់និយ័តករមូលបត្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព ក្រោមឱវាទនៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងការៈ ទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចរបស់និយ័តករធានារ៉ាប់រងកម្ពុជា។

## សិក្ខាសាលាស្តីពី “ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬ សេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច”

នាព្រឹកថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែមីនា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី “ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច” ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តមបណ្ឌិត លុយ ចន្ថា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធន-បាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, **លោក សាធ ភីរ៉ាត ប្រធាននាយកដ្ឋានប្រតិបត្តិការពាណិជ្ជលក់រាយ** វាគ្មិនតំណាងពីធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់, ថ្នាក់ដឹកនាំ, សាស្ត្រាចារ្យ, និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចំនួន២៤០ រូប។



រូបភាព៖ កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងការៈ ទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចរបស់និយ័តករធានារ៉ាប់រងកម្ពុជា។

## កិច្ចប្រជុំចាប់ផ្តើមកម្រិតថ្នាក់ដឹកនាំ (High level Kick-off) លើគម្រោងជំនួយបច្ចេកទេសស្តីពី ការរៀបចំ “របាយការណ៍ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ”

នារសៀលថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែមីនា គ.ស. ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំចាប់ផ្តើមកម្រិតថ្នាក់ដឹកនាំ (High level Kick-off) លើគម្រោងជំនួយបច្ចេកទេសស្តីពី ការរៀបចំ “របាយការណ៍ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ” ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.**។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ឯកឧត្តមអគ្គនាយកនិយ័តករក្រោមឱវាទ **អ.ស.ហ.** តំណាងការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) និងតំណាងវិទ្យាស្ថានអភិវឌ្ឍន៍ទីផ្សារមូលធនកូរ៉េ (KCMI)។



រូបភាព៖ កិច្ចប្រជុំចាប់ផ្តើមកម្រិតថ្នាក់ដឹកនាំ (High level Kick-off) លើគម្រោងជំនួយបច្ចេកទេសស្តីពី ការរៀបចំ “របាយការណ៍ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ”។

## សិក្ខាសាលាស្ដីពី "ការចែករំលែកអំពីយន្តការបរធនបាលកិច្ចអចលនវត្ថុ"

កាលពីល្ងាចថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែមីនា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ដើម្បីធ្វើការចែករំលែកអំពីយន្តការបរធន-បាលកិច្ចអចលនវត្ថុ នៅវិទ្យាស្ថានខេមអេដ ដោយមានកិច្ចសម្រប-សម្រួលពី **បណ្ឌិត ព្រំ វីរៈ** ប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានខេមអេដ។ កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីបង្កើនការយល់ដឹងអំពីយន្តការបរធនបាលកិច្ចអចលនវត្ថុ ចែករំលែកអំពីស្ថានភាពទីផ្សារបរធនបាលកិច្ចនាពេលបច្ចុប្បន្ន និងនិន្នាការអនាគត ព្រមទាំងពិភាក្សាអំពីក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ និងការអនុវត្តផងដែរ។ កម្មវិធីនេះ មានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថាន ខេមអេដ វិស័យឯកជន និងសាធារណជន។



រូបភាព៖ សិក្ខាសាលាស្ដីពី "ការចែករំលែកអំពីយន្តការបរធនបាលកិច្ចអចលនវត្ថុ"។

## សិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈអំពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល"

នៅព្រឹកថ្ងៃសុក្រ ១៤ រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈអំពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល" នៅទីស្ដីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមដល់ក្រុមហ៊ុនបរធនបាលដើម្បីស្វែងយល់ពីអំពីលក្ខខណ្ឌ និងនីតិវិធីក្នុងការត្រួតពិនិត្យលើភាពរឹងមាំហិរញ្ញវត្ថុនិងកាតព្វកិច្ចផ្សេងៗរបស់ក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី **ន.ប.ធ.** សំដៅដល់ការធានាលើប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្ដាប់ធ្នាប់ របៀបរៀបរយ និងទទួលបានទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងក្រុមហ៊ុនបរធនបាល, ប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្ដល់សេវាសវនកម្មដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ពី **ន.ប.ធ.** ។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈអំពីការដាក់ឱ្យអនុវត្តប្រកាសស្ដីពី "លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888